

# របាយការណ៍ប្រចាំឆ្នាំ ២០១៧

## អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

LBP
MICROFINANCE

# មាតិកា

ទំព័រ:

១. សារពីគណៈគ្រប់គ្រង............................................................ ០៤-០៥

២. អំពីយើង............................................................................ ០៦

- ប្រវត្តិគ្រឹះស្ថាន.................................................................... ០៦
- ចក្ខុវិស័យរបស់យើង............................................................ ០៦
- បេសកកម្មរបស់យើង............................................................ ០៦
- គុណតំលៃរបស់យើង............................................................ ០៧

៣. សមិទ្ធផលរបស់យើង............................................................ ០៨

៤. អភិបាលកិច្ច.......................................................................... ០៩

- រចនាសម្ព័ន្ធ អិលប៊ីភី.............................................................. ០៩
- ភាគទុនិក និងក្រុមប្រឹក្សាភិបាល........................................... ១០
- គណៈគ្រប់គ្រង...................................................................... ១១

៥. របាយការណ៍សវនករឯករាជ្យ.................................................. ១២

- មតិយោបល់...................................................................... ១២-១៣
- តារាងតុល្យការណ៍................................................................. ១៤
- របាយការណ៍លទ្ធផល............................................................ ១៥
- របាយការណ៍បម្រែបម្រួលមូលធន.......................................... ១៦
- របាយការណ៍លំហូរសាច់ប្រាក់..............................................១៧

# ១. សារពីគណៈគ្រប់គ្រង





អិល ប៊ី ភី មី ក្រុហិរញ្ញវត្ថុ ភីអិលស៊ី បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅខែសីហា ឆ្នាំ២០១៦ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គោលបំណងចំបងបំផុតរបស់យើង គឺចង់ផ្តល់ឱកាសឱ្យសហគ្រិនកម្ពុជាទទួលបាននូវមូលធន គ្រប់គ្រាន់ក្នុងការវិនិយោគជំនួញរបស់ពួកគេ តាមរយៈការប្រើប្រាស់ប្រាក់កម្ចីរបស់ អិល ប៊ី ភី ។ យើងតែងតែខិតខំប្រឹងប្រែងផ្តល់ឱ្យ អតិ ថិជននូវសេវាកម្មដ៏ល្អបំផុតជាមួយនឹងអត្រាការប្រាក់ដែលមានភាពប្រកួតប្រជែង និងរយៈពេលខ្ចីសមរម្យ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អតិថិជនក្នុងការប្រើ ប្រាស់ប្រាក់កម្ចីប្រកបដោយនិរន្តរ៍ភាព។ យើងមានប្រភពទុនរឹងមាំ ច្បាស់លាស់ព្រមទាំងមានថ្នាក់ដឹកនាំ ដែ លមានសមត្ថភាព ជំនាញ ចំណេះដឹង និងបទពិសោធន៍ជាច្រើនឆ្នាំក្នុងវិស័យហិរញ្ញវត្ថុដែលអាចធានានូវស្ថេរភាពនិងការរីកចំរើនរបស់ អិលប៊ីភី។ លើសពីនេះទៅទៀត យើងក៏បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងប្រាក់កម្ចីដែលអាចធានាបាននូវសុវត្ថិភាពព័ត៌មានរបស់ក្រុមហ៊ុន និងអតិថិជន។ ប្រព័ន្ធនេះក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការគ្រប់គ្រងទិន្នន័យការធ្វើរបាយការណ៍ និងជំរុញឱ្យការផ្តល់សេវាកម្មទៅកាន់អតិថិជន បានឆាប់រហ័សនិងអាចជឿទុកចិត្តបានថែមទៀតផង។ យើងក៏បានសហការជាមួយធនាគារឯកទេស វីង (ខេមបូឌា) ក្រុមហ៊ុន ទ្រូម៉ាន់នី(ខេម បូឌា) និងក្រុមហ៊ុន វៀតធេល(ខេមបូឌា) ដែលអនុញ្ញាតិឱ្យអតិថិជនរបស់ អិលប៊ីភី ទាំងអស់អាចធ្វើការសងត្រឡប់មកគ្រឹះស្ថានវិញតាមរយៈទូរស័ព្ទដៃឬភ្នាក់ងារទាំងអស់របស់ក្រុមហ៊ុនទាំងបីខាងលើដែលមាននៅទូទាំងប្រទេស។កត្តានេះវាបានបង្កលក្ខណៈងាយស្រួល

និងកាត់បន្ថយហានិភ័យផ្សេងៗដល់អតិថិជនក្នុងការសងត្រឡប់មក អិលប៊ីភី វិញ ។ ក្នុងនាមជាថ្នាក់ដឹកនាំរបស់គ្រឹះស្ថាន អិលប៊ីភី មីក្រូហិរញ្ញវត្ថុ យើងខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅបំផុតដល់ភាគទុនិករបស់ក្រុមហ៊ុនសមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិកគ្រប់ជាន់ថ្នាក់ដៃគូរសហប្រតិបត្តិការ និងអតិថិជនទាំងអស់ដែលបានគាំទ្រដល់គ្រឹះស្ថានរបស់យើងឱ្យមានដំណើរការល្អរហូត ដល់ពេលបច្ចុប្បន្ន។ យើងក៏សូមថ្លែងអំណរគុណជាពិសេសដល់ធនាគារជាតិនៃកម្ពុជាដែលបានផ្តល់អាជ្ញាប័ណ្ណអោយ អិលប៊ីភី ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយយើងខ្ញុំសង្ឃឹមយ៉ាងម៉ុតមាំថា អិលប៊ីភី នឹងក្លាយជាចំណែកមួយក្នុងការជួយសម្រាលបន្ទុករបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនៅកម្ពុជាតាមរយៈ ការផ្តល់ប្រាក់កម្ចីដល់សហគ្រិនតូច និងមធ្យមទាំងអស់។ យើងប្តេជ្ញាចិត្តថា នឹងព្យាយាមអភិវឌ្ឍផលិតផលប្រាក់កម្ចីរបស់ខ្លួនឱ្យបានល្អ ដើម្បីឆ្លើយតបទៅនឹងតម្រូវការធនធានរបស់សហគ្រិនកម្ពុជាទាំងអស់ប្រកបដោយតម្លាភាពនិងភាពស្មោះត្រង់បំផុត៕

**លោក ឡាយ ប៊ុណ្ណាវឌ្ឍន៍**
**នាយគ្រប់គ្រង**

**លោក មួង សម្បត្តិ**
**នាយប្រតិបត្តិ**

# ២. អំពីយើង

## ប្រវត្តិគ្រឹះស្ថាន

គ្រឹះស្ថាន អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ដែលបង្កើតឡើងដោយភាគទុនិកក្នុងស្រុកពីររូបគឺ លោកឧកញ៉ា ឡាយ ប៊ុន ប៉ា និងលោកជំទាវ ឡាយ ឈុននី និងទទួលបាន អាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៦ ។

គ្រឹះស្ថាន អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី គឺជាគ្រឹះស្ថានឯកជន ដែលផ្តល់សេវាហិរញ្ញវត្ថុដល់ពលរដ្ឋកម្ពុជា ជាលក្ខណៈខ្នាតតូច និងមធ្យមក្នុងអត្រាការប្រាក់ និងរយៈពេលខ្ចីល្អបំផុត ដើម្បីធានាឲ្យបាននូវតម្លាភាពជូនដល់អតិជន ព្រមទាំងរួមចំណែកលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជាអោយបានកាន់តែល្អប្រសើរ។

## ទស្សនៈវិស័យ

ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ព្រមទាំងគាំទ្រដល់សហគ្រិនកម្ពុជាដែលមានសក្តានុពលឲ្យសម្រេចបានពេញលេញនូវគោលដៅអាជីវកម្មរបស់ខ្លួន តាមរយៈការផ្តល់ប្រាក់កម្ចីប្រកបដោយតម្លាភាព គណនេយ្យភាព គុណភាព និងនិរន្តរភាព។

## បេសកកម្ម

- ផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋ និងសហគ្រិនកម្ពុជាដែលមានសក្តានុពល ក្នុងកម្រិតអត្រាការប្រាក់សមរម្យ និងសេវាកម្មរហ័សប្រកបដោយការទទួលខុសត្រូវ ។
- ផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលទាំងអតិថិជនទាំងគ្រឹះស្ថាន ។



## គុណតម្លៃ

- **ភាពស្មោះត្រង់:** យើងនឹងផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មប្រកបដោយសុចរិតភាព ភាពស្មោះត្រង់ និងគុណធម៌ ។
- **ទំនួលខុសត្រូវ:** យើងនឹងផ្តល់ជូនអតិថិជននូវផលិតផលនិងសេវាកម្មប្រកបដោយវិជ្ជាជីវៈ ទំនួលខុសត្រូវខ្ពស់ និងឆ្លើយតបទាន់ពេលវេលារាល់តម្រូវការរបស់អតិថិជន ។
- **ផ្តល់តម្លៃ:** យើងចាត់ទុកអតិថិជន បុគ្គលិក និងអ្នកពាក់ព័ន្ធទាំងអស់ជាទ្រព្យសម្បត្តិ ព្រមទាំងផ្តល់តម្លៃ និងការគោរពចំពោះពួកគេដោយគ្មានការរើសអើង ។
- **ផ្តល់អាទិភាព:** យើងនឹងផ្តល់សេវាកម្មដ៏ល្អឥតខ្ចោះលើសពីអ្វីដែលអតិថិជនចង់បាន។អតិថិជនគឺជាអាទិភាពចំបងរបស់ អិលប៊ីភី ។

# ៣.សមិទ្ធផលរបស់យើង



# ៤.អភិបាលកិច្ច

## រចនាសម្ព័ន្ធ អិល ប៊ី ភី ឆ្នាំ ២០១៧



# ភាគទុនិក និងក្រុមប្រឹក្សាភិបាល



លោកឧកញ៉ា ឡាយ ប៊ុន ប៉ា
ប្រធានក្រុមប្រឹក្សាភិបាល និងភាគទុនិក



លោកជំទាវ ឡាយ ឈុន នី
សមាជិកក្រុមប្រឹក្សាភិបាល និងភាគទុនិក



លោក ឡាយ ប៊ុណ្ណាវឌ្ឍន៍
សមាជិកក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រងទូទៅ



អ្នកស្រី ឡាយ ម៉ូនីកា
សមាជិកក្រុមប្រឹក្សាភិបាល



អ្នកស្រី ឡាយ ឌីណា
សមាជិកក្រុមប្រឹក្សាភិបាល



លោក ប៊ូ រស់
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ



លោក មួង សម្បត្តិ
សមាជិកក្រុមប្រឹក្សាភិបាល និងជានាយកប្រតិបត្តិ

# គណៈគ្រប់គ្រង



**ឡាយ ប៊ុណ្ណាវឌ្ឍន៍**
**នាយកគ្រប់គ្រងទូទៅ**

លោក ប៊ុណ្ណាវឌ្ឍន៍ គឺជាតំណាងរបស់ប្រធានក្រុមប្រឹក្សាភិបាលនៅ អិលប៊ីភី ។ លោកបានបញ្ចប់ការសិក្សាអនុបណ្ឌិតហិរញ្ញវត្ថុពីប្រទេសអង់គ្លេស និងមានបទពិសោធន៍ជាច្រើនឆ្នាំលើការគ្រប់គ្រងទូទៅផងដែរ។



**មួង សម្បត្តិ**
**នាយកប្រតិបត្តិ**

លោក សម្បត្តិ បានបញ្ចប់ការសិក្សាផ្នែកឯកទេសធនាគារនៅសាលាធនាគារជាតិនៃកម្ពុជា និងមានបទពិសោធន៍ខាងវិស័យធនាគារ និងហិរញ្ញវត្ថុជាង៣០ឆ្នាំ ដោយធ្លាប់ធ្វើការនៅតាមធនាគាររដ្ឋ ធនាគារឯកជន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន ហើយលោកក៏ជាអ្នកចូលរួមក្នុងការបង្កើតអិលប៊ីភីផងដែរ។



**យុន ដារុធ**
**ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

លោ ក ដារុធ បានបញ្ចប់បរិញ្ញាបត្រផ្នែក គណនេយ្យ។ លោកមា នបទពិសោធន៍ជាង ១០ឆ្នាំលើផ្នែកគណនេយ្យនិងហិរញ្ញវត្ថុនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ លោកចាប់ផ្តើមជាមួយអិលប៊ីភីនៅក្នុងឆ្នាំ២០១៦ ។



**ជិន ណុប**
**ប្រធាននាយកដ្ឋានប្រតិបត្តិការ**

លោក ណុប មានបទពិសោធន៍ជាង១០ឆ្នាំលើផ្នែកឥណទាន និងបានចូលរួមជាមួយ អិលប៊ីភី ក្នុងឆ្នាំ២០១៦។ លោកបានបញ្ចប់បរិញ្ញបត្រផ្នែកគ្រប់គ្រង និងអនុបណ្ឌិតផ្នែកគ្រប់គ្រង។



**យិន សន្តិភាព**
**ប្រធានផ្នែកឥណទាន**

លោក សន្តិភាព មានបទពិសោធន៍ជាង១០ឆ្នាំលើផ្នែកឥទាន និងបានចូលបម្រើការងារជាមួយ អិលប៊ីភី នៅក្នុងឆ្នាំ២០១៦ ។ លោកបញ្ចប់បរិញ្ញាបត្រអភិវឌ្ឍន៍សេដ្ឋកិច្ចនិងអនុបណ្ឌិត ផ្នែកជំនួញ ។

# ៥. របាយការណ៍សវនករឯករាជ្យ

## របាយការណ៍សវនករឯករាជ្យ

### ជូនភាគទុនិក គ្រឹះស្ថាន អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមគោលការណ៍ណែនាំរបស់ ធនាគារជាតិ នៃ កម្ពុជានិងស្តង់ដារគណនេយ្យកម្ពុជា។

### របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន៖

- តារាងតុល្យការគិតត្រឹមថ្ងៃទីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧
- របាយការណ៍លទ្ធផលសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ។

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា(ហៅកាត់ថា "ស្តង់ដារសវនកម្ម") ។ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ "ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីក្រុមហ៊ុន ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "ក្រមសីលធម៌ វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយ "ក្រមសីលធម៌អន្តរជាតិ" និងក្រមសីលធម៌ វគសក។

### ព័ត៌មានផ្សេងៗ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។
ព័ត៌មានផ្សេងៗរួមមាន របាយការណ៍ក្រុមប្រឹក្សាភិបាល និងឧបសម្ព័ន្ធកំណត់សម្គាល់ចំពោះ ការអនុវត្តតាមប្រកាសរបស់ធនាគារកណ្តាលគិតត្រឹមការិយបរិច្ឆេទ រាយការណ៍របស់សវនករ ប៉ុន្តែព័ត៌មានទាំងនេះមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។ មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។
ទាក់ទង នឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្ត ពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។
ផ្អែកទៅលើការងារ ដែលយើងខ្ញុំបានបំពេញទៅលើព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួល មុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗ ទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

### បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុ រួមមាន ព័ត៌មានប្រៀបធៀបដែលតម្រូវតាមស្តង់ដារគណនេយ្យកម្ពុជា១ ស្តីពី "ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ"។ ព័ត៌មានប្រៀបធៀបគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងសម្រាប់ការិយបរិច្ឆេទពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ (ការិយបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម) ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មិនបានធ្វើសវនកម្ម។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជានិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។
ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែល

ពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់ និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេង ប្រកបដោយភាពប្រាកដប្រជាណាមួយ។ អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការ នៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺស្វែងរកអំណះអំណាង ដែលសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមាន ការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមក ពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើង ដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុបអាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាន នៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឲ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាភាពងឿងឆ្ងល់ប្រកបដោយវិជ្ជាជីវៈ ក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមក ពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំវាមានទំហំធំជាងហានិភ័យ ដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមានការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុសឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ភាពសមហេតុផលនៃការប៉ាន់ ស្មានគណនេយ្យនិងការលាតត្រដាង ពាក់ព័ន្ធដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់ មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រងអាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើង ខ្ញុំទទួលបានថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្ត ដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឲ្យមានការសង្ស័យជាដុំកំភួន ទៅលើលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើងនោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។
សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំអាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបានរហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ឬលក្ខខណ្ឌនានាក្នុងពេលអនាគតអាចបណ្តាលឲ្យក្រុមហ៊ុនឈប់បន្តនិរន្តរភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឲ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុក អភិបាលកិច្ច នូវបញ្ហាផ្សេងៗដូចជាទំហំការងារនិងពេលវេលាសវនកម្មព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

**ជ. ក្រុមហ៊ុន** PricewaterhouseCoopers (Cambodia) Ltd.



**ឡាង ហ៊ី**
Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨

# តារាងតុល្យការ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | គិតត្រឹម ៣១ ធ្នូ ២០១៧ | | គិតត្រឹម ៣១ ធ្នូ ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិច** | **ពាន់រៀល** | **ដុល្លារអាមេរិច** | **ពាន់រៀល** |
| | | | មិនបានធ្វើសវនកម្ម | មិនបានធ្វើសវនកម្ម |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៩៣.០៦៣ | ៣៧៥.៦៩៥ | ១២.៩៨០ | ៥២.៤០០ |
| សមតុល្យនៅធនាគារកណ្តាល | ៦៣.៧៤១ | ២៥៧.៣២២ | ៥១.០៣៨ | ២០៦.០៤០ |
| សមតុល្យនៅធនាគារផ្សេងៗ | ៦៩.៧៨៣ | ២៨១.៧១៤ | ២៩០ | ១.១៧១ |
| ឥណទានអតិថិជន | ៣.១៧៨.៤១៤ | ១២.៨៣១.២៥៧ | ៨១៥.០៩១ | ៣.២៩០.៥២២ |
| ទ្រព្យសកម្មផ្សេងៗ | ១៤៣.៤២៤ | ៥៧៩.០០៣ | ៨២.៣១៦ | ៣៣២.៣១០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១០៣.៥៨៧ | ៤១៨.១៨១ | ៩១.៦៣៣ | ៣៦៩.៩២២ |
| ទ្រព្យសកម្មអរូបី | ៣៥.៦៤០ | ១៤៣.៨៧៩ | ១៦.៣៤៥ | ៦៥.៩៨៥ |
| ពន្ធពន្យារទ្រព្យសកម្ម | ៨២១ | ៣.៣១៤ | - | - |
| **ទ្រព្យសកម្មសរុប** | **៣.៦៨៨.៤៧៣** | **១៤.៨៩០.៣៦៥** | **១.០៦៩.៦៩៣** | **៤.៣១៨.៣៥០** |
| | | | | |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| ប្រាក់កម្ចី | ២.៥៨៩.០១៣ | ១០.៤៥១.៨៤៥ | - | - |
| បំណុលផ្សេងៗ | ៧៩.៩៦២ | ៣២២.៨០៧ | ២៣៨.៥២២ | ៩៦២.៩១៣ |
| បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា | - | - | ២២០ | ៨៨៨ |
| **បំណុលសរុប** | ២.៦៦៨.៩៧៥ | ១០.៧៧៤.៦៥២ | ២៣៨.៧៤២ | ៩៦៣.៨០១ |
| | | | | |
| **មូលធន** | | | | |
| ដើមទុន | ១.២៥០.០០០ | ៥.០៤៦.២៥០ | ១.០០០.០០០ | ៤.០៣៧.០០០ |
| ខាតបង្គរ | (២៣០.៥០២) | (៩៣០.៥៣៧) | (១៦៩.០៤៩) | (៦៨២.៤៥១) |
| **មូលធនសរុប** | ១.០១៩.៤៩៨ | ៤.១១៥.៧១៣ | ៨៣០.៩៥១ | ៣.៣៥៤.៥៤៩ |
| **បំណុល និងមូលធនសរុប** | ៣.៦៨៨.៤៧៣ | ១៤.៨៩០.៣៦៥ | ១.០៦៩.៦៩៣ | ៤.៣១៨.៣៥០ |

# របាយការណ៍លទ្ធផល

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | សម្រាប់ដំណាច់ឆ្នាំ៣១ ធ្នូ ២០១៧ | | សម្រាប់ការិយបរិច្ឆេទពី១៧ វិច្ឆិកា ២០១៥ (ការិយបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម) ដល់ ៣១ ធ្នូ ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិច** | **ពាន់រៀល** | **ដុល្លារអាមេរិច** | **ពាន់រៀល** |
| | | | មិនបានធ្វើសវនកម្ម | មិនបានធ្វើសវនកម្ម |
| ចំណូលការប្រាក់ | ៣៧៧.២៧២ | ១.៥២៣.០៤៧ | ១៥.៨៣៧ | ៦៣.៩៣៤ |
| ចំណាយការប្រាក់ | (១១៩.៩៣៤) | (៤៨៤.១៧៤) | - | - |
| **ចំណូលការប្រាក់សុទ្ធ** | ២៥៧.៣៣៨ | ១.០៣៨.៨៧៣ | ១៥.៨៣៧ | ៦៣.៩៣៤ |
| ចំណូលកម្រៃ និងជើងសា | ៥៣.២៤៣ | ២១៤.៩៤២ | ៦.០៦៤ | ២៤.៤៨០ |
| សំវិធានធនឥណទានបាត់បង់ | (១.០៦៧) | (៤.៣០៧) | - | - |
| **ចំណូលសុទ្ធបន្ទាប់ពីសំវិធានធន** | ៣០៩.៥១៤ | ១.២៤៩.៥០៨ | ២១.៩០១ | ៨៨.៤១៤ |
| ចំណូលផ្សេងៗ | ២៩.៩២៦ | ១២០.៨១១ | ៧៣ | ២៩៩ |
| ចំណាយបុគ្គលិក | (២០១.១២០) | (៨១១.៩២១) | (៤៨.០០១) | (១៩៣.៧៨០) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | (២៥.០៤៥) | (១០១.១០៧) | (៧.៩៥៩) | (៣២.១៣៥) |
| ចំណារំលស់ទ្រព្យសកម្មអរូបី | (៨.៩១០) | (៣៥.៩៧០) | - | - |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | (១៦៦.៦៣៩) | (៦៧២.៧២២) | (១៣៥.០៦៣) | (៥៤៥.២៤៩) |
| | (៣៧១.៧៨៨) | (១.៥០០.៩០៩) | (១៩០.៩៥០) | (៧៧០.៨៦៥) |
| **ខាតមុនបង់ពន្ធលើប្រាក់ចំណេញ** | (៦២.២៧៤) | (២៥១.៤០១) | (១៦៩.០៤៩) | (៦៨២.៤៥១) |
| ចំណាយពន្ធលើប្រាក់ចំណេញ | ៨២១ | ៣.៣១៤ | - | - |
| **ខាតសុទ្ធក្នុងឆ្នាំ/ការិយបរិច្ឆេទ** | (៦១.៤៥៣) | (២៤៨.០៨៧) | (១៦៩.០៤៩) | (៦៨២.៤៥១) |
| **បែងចែកឲ្យម្ចាស់ក្រុមហ៊ុន** | (៦១.៤៥៣) | (២៤៨.០៨៧) | (១៦៩.០៤៩) | (៦៨២.៤៥១) |

# របាយការណ៍បម្រែបម្រួលមូលធន

## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

**បែងចែកឲ្យម្ចាស់ក្រុមហ៊ុន**

| | ដើមទុន | ខាតបង្គរ | សរុប |
|---|---|---|---|
| | ដុល្លារអាមេរិច | ដុល្លារអាមេរិច | ដុល្លារអាមេរិច |
| **សម្រាប់ការិយបរិច្ឆេទពី១៧ វិច្ឆិកា ២០១៥ (ការិយបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម) ដល់ ៣១ ធ្នូ ២០១៦** (ការិយបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម) | | | |
| (មិនបានធ្វើសវនកម្ម) | - | - | - |
| ការបន្ថែមដើមទុន | ១.០០០.០០០ | - | ១.០០០.០០០ |
| ខាតក្នុងការិយបរិច្ឆេទសុទ្ធ | - | (១៦៩.០៤៩) | (១៦៩.០៤៩) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ (មិនបានធ្វើសវនកម្ម) | ១.០០០.០០០ | (១៦៩.០៤៩) | ៨៣០.៩៥១ |
| គិតជាពាន់រៀល (មិនបានធ្វើសវនកម្ម) | ៤.០៣៧.០០០ | (៦៨២.៤៥១) | ៣.៣៥៤.៥៤៩ |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ១.០០០.០០០ | (១៦៩.០៤៩) | ៨៣០.៩៥១ |
| ការបន្ថែមដើមទុន | ២៥០.០០០ | - | ២៥០.០០០ |
| ខាតក្នុងឆ្នាំសុទ្ធ | - | (៦១.៤៥៣) | (៦១.៤៥៣) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ១.២៥០.០០០ | (២៣០.៥០២) | ១.០១៩.៤៩៨ |
| គិតជាពាន់រៀល | ៥.០៤៦.២៥០ | (៩៣០.៥៣៧) | ៤.១១៥.៧១៣ |

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | សម្រាប់ដំណាច់ឆ្នាំ៣១ ធ្នូ ២០១៧ | | សម្រាប់ការិយបរិច្ឆេទពី១៧ វិច្ឆិកា ២០១៥ (ការិយបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម) ដល់ ៣១ ធ្នូ ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិច** | **ពាន់រៀល** | **ដុល្លារអាមេរិច** | **ពាន់រៀល** |
| | | | មិនបានធ្វើសវនកម្ម | មិនបានធ្វើសវនកម្ម |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ | (២.៤០១.៨៣៧) | (៩.៦៩៦.២១៦) | (៨១៩.៧៥៥) | (៣.៣០៩.៣៥១) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ប្រាក់តម្កល់ធានាលើដើមទុនជាមួយធនាគារកណ្តាល | (១២.៥០០) | (៥០.៤៦៣) | (៥០.០០០) | (២០១.៨៥០) |
| ទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (៣៦.៩៩៩) | (១៤៩.៣៦៥) | (៩៩.៥៩២) | (៤០២.០៥៣) |
| ទិញទ្រព្យសកម្មអរូបី (*) | (១១.៣៨៥) | (៤៥.៩៦១) | (១៦.៣៤៥) | (៦៥.៩៨៥) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | (៦០.៨៨៤) | (២៤៥.៧៨៩) | (១៦៥.៩៣៧) | (៦៦៩.៨៨៨) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់បានមកពីការបន្ថែមដើមទុន | ២៥០.០០០ | ១.០០៩.២៥០ | ១.០០០.០០០ | ៤.០៣៧.០០០ |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ២.៣៦២.៥០០ | ៩.៥៣៧.៤១៣ | - | - |
| សាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន | ២.៦១២.៥០០ | ១០.៥៤៦.៦៦៣ | ១.០០០.០០០ | ៤.០៣៧.០០០ |
| **កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | ១៤៩.៧៧៩ | ៦០៤.៦៥៨ | ១៤.៣០៨ | ៥៧.៧៦១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ/ការិយបរិច្ឆេទ | ១៤.៣០៨ | ៥៧.៧៦១ | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ/ការិយបរិច្ឆេទ** | ១៦៤.០៨៧ | ៦៦២.៤១៩ | ១៤.៣០៨ | ៥៧.៧៦១ |

(*) លំហូរសាច់ប្រាក់មិនរួមបញ្ចូលប្រតិបត្តិការមិនមែនសាច់ប្រាក់ដែលមានចំនួន ១៦.៨២០ ដុល្លារអាមេរិក។